**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា
# សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធានគ.ជ.អ.ប
# ក្នុងពិធីបិទ
# សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់ គ.ជ.អ.ប

សាលប្រជុំក្រសួងមហាផ្ទៃ, ថ្ងៃព្រហស្បតិ៍ ៩ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ
២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានីខេត្ត**
- **ឯកឧត្តម លោកជំទាវតំណាងក្រសួងស្ថាប័ននានា**
- **អស់លោក លោកស្រីតំណាងដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល**
- **អស់លោក លោកស្រីជាសមាជិក សមាជិកានៃអង្គសិក្ខាសាលាជាទីមេត្រី**

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានចូលរួមក្នុងពិធីបិទសិក្ខាសាលាជាតិស្តីពី "ការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់ គ.ជ.អ.ប" ដែលបានប្រព្រឹត្តទៅអស់រយៈពេលមួយថ្ងៃកន្លងទៅនេះ។ យោងតាមរបាយការណ៍ បានបង្ហាញឱ្យយើងឃើញថា សិក្ខាសាលាបានប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា ដោយមានការចូលរួមយ៉ាងសកម្មពីអង្គសិក្ខាសាលាទាំងមូល និងបានផ្តល់នូវយោបល់ដ៏មានតម្លៃជាច្រើនទាំងទៅលើការអនុវត្តសកម្មភាពកំណែទម្រង់នាឆ្នាំកន្លងមក និងទៅលើសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០២០ របស់ គ.ជ.អ.ប ដែលជាផែនការសម្រាប់អនុវត្តនៅឆ្នាំចុងក្រោយនៃកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្នុងនាមរាជរដ្ឋាភិបាល និង គ.ជ.អ.ប ខ្ញុំសូមឆ្លៀតឱកាសនេះសម្តែងនូវការកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមចំណែករបស់ឯកឧត្តម លោកជំទាវ អស់លោកលោកស្រីទាំងអស់ក្នុងការបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្រោមក្របខ័ណ្ឌគោលនយោបាយ និងរបៀបវារៈនានានៃការអភិវឌ្ឍជាតិ។

ទោះបីជាយើងប្រមើលមើលឃើញថា សកម្មភាពដែលបានគ្រោងទុកមួយចំនួនមិនអាចបញ្ចប់នៅចុងឆ្នាំនេះ ប៉ុន្តែក្នុងឆ្នាំ២០១៩នេះ យើងបានសម្រេចនូវសកម្មភាពជាច្រើនគួរឱ្យកត់សម្គាល់ដែលបង្កជាមូលដ្ឋានគ្រឹះដ៏រឹងមាំដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅចុងក្រោយនៃកំណែទម្រង់នេះ។

អ្វីដែលជាសមិទ្ធផលដ៏សំខាន់ និងចាត់ទុកថាមានលក្ខណៈជាប្រវត្តិសាស្ត្រនៃកិច្ចដំណើរការកំណែទម្រង់ដែលយើងសម្រេចបានក្នុងឆ្នាំ២០១៩នេះ គឺការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការប្រគល់មុខងារពាក់ព័ន្ធនឹងវិស័យជាច្រើនទៅឱ្យរដ្ឋបាលទាំងនេះ និងការផ្ទេរមុខងារសុខាភិបាលដែលធ្លាប់បានអនុវត្តដោយមន្ទីរសុខាភិបាល ទៅឱ្យស្ថិតក្រោមការគ្រប់គ្រងចាត់ចែងរដ្ឋបាលរាជធានី ខេត្ត។ ជារួមយើងបានសហការគ្នារៀបចំកិច្ចការនេះតាំងពីឆ្នាំ២០១៦កន្លងមក ដោយមានការពិគ្រោះយោបល់គ្នាជាបន្តបន្ទាប់ដោយផ្អែកលើក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្តិ និងស្ថានភាពនៃការអនុវត្តជាក់ស្តែង។ ក្នុងគោលបំណងជំរុញឱ្យរចនាសម្ព័ន្ធថ្មីទាំងនេះអាចចាប់ផ្តើមបំពេញការងាររបស់ខ្លួនចាប់ពីដើមឆ្នាំ២០២០តទៅ នាពេលថ្មីៗកន្លងមកនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យចំនួន៣ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យមួយទៀតស្តីពីការផ្ទេរមុខងារសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។

លទ្ធផលជាគន្លឹះមួយទៀតដែលយើងសម្រេចបានក្នុងឆ្នាំនេះ ពាក់ព័ន្ធទៅនឹងការបង្កើនមូលនិធិឃុំ សង្កាត់ដើម្បីបង្កលក្ខណៈឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កាន់តែមានលទ្ធភាពអាចចូលរួមដោះស្រាយនូវតម្រូវការជាអាទិភាពនានារបស់មូលដ្ឋាននីមួយៗ។ ផ្អែកលើអនុក្រឹត្យរបស់រាជរដ្ឋាភិបាលស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ដែលបានដាក់ចេញនាខែសីហាឆ្នាំ២០១៩កន្លងមក នៅឆ្នាំ២០២០ខាងមុខនេះ ឃុំសង្កាត់នីមួយៗនឹងទទួលបានថវិកាសរុបជាមធ្យមចំនួនប្រមាណ១២២.០០០ដុល្លារ ក្នុងនោះរួមមានថវិកាសម្រាប់ចំណាយលើផ្នែកអភិវឌ្ឍមូលដ្ឋានចំនួនប្រមាណជាង ៧០.០០០ដុល្លារដែលចំនួននេះកើនឡើងទ្វេដងបើប្រៀបធៀបនឹងឆ្នាំ២០១៩នេះ។ ថវិកានេះនឹងកើនឡើងជារៀងរាល់ឆ្នាំ ដែលរហូតដល់ឆ្នាំ២០២៣ រដ្ឋបាលឃុំ សង្កាត់នីមួយៗនឹងទទួលបានថវិកាសរុបជាមធ្យមចំនួនជាង១៣២.០០០ដុល្លារ។ ជាមួយនឹងការកើនឡើងដ៏គំហុកនេះនឹងធ្វើឱ្យឃុំ សង្កាត់ដែលនឹងទទួលបានថវិកាសរុបច្រើនជាងគេ មានរហូតដល់ចំនួនប្រមាណ៤៥០.០០០ដុល្លារនៅឆ្នាំ២០២៣ ឧទាហរណ៍ដូចជា សង្កាត់ប៉ោយប៉ែតនៃក្រុងប៉ោយប៉ែត និងឃុំក្រែកនៃស្រុកពញាក្រែកជាដើម។

ក្រៅពីសមិទ្ធផលសំខាន់ទាំង២ខាងលើនេះ យើងបានធ្វើឱ្យមានវឌ្ឍនភាពជាច្រើនពាក់ព័ន្ធការពិនិត្យមើលកែសម្រួលឡើងវិញ និងការដាក់ចេញនូវគោលនយោបាយនានាដែលគាំទ្រដល់ការលើក

កម្ពស់គុណភាពនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលក្នុងនោះរួមមានដូចជា គោលនយោបាយស្តីពីយេនឌ័រ គោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមជាដើម។ សកម្មភាពជាច្រើនពាក់ព័ន្ធនឹងការលើកកម្ពស់ការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិក៏បានត្រូវបន្តពង្រឹងថែមទៀតតាមរយៈការអនុវត្តការងារគណនេយ្យភាពសង្គម។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

យើងនៅសល់ពេលវេលាមិនដល់មួយខែទេសម្រាប់ឆ្នាំ២០១៩នេះ។ ជាមួយនឹងរយៈពេលដែលនៅសេសសល់តិចតួចនេះ យើងត្រូវខិតខំប្រឹងប្រែងបន្តសម្រេចនូវសកម្មភាពជាអាទិភាពនានាដែលបានគ្រោងទុកសម្រាប់ឆ្នាំនេះផង និងសម្របសម្រួលឱ្យមានការឯកភាពគ្នាលើផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំបន្ទាប់ខាងមុខនេះផង។

អាស្រ័យហេតុនេះ មុននឹងផ្តល់ការណែនាំមួយចំនួនទៅលើផែនការសកម្មភាពសម្រាប់ឆ្នាំ ២០២០ ខ្ញុំសូមឆ្លៀតឱកាសនេះគូសបញ្ជាក់អំពីកិច្ចការជាអាទិភាពមួយចំនួនដែលយើងទាំងអស់គ្នាត្រូវប្រមូលផ្តុំការយកចិត្តទុកដាក់អនុវត្តឱ្យបានមុនដំណាច់ឆ្នាំនេះដើម្បីធានាឱ្យរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនានាអាចចាប់ផ្តើមបំពេញការងាររបស់ខ្លួនពីដើមឆ្នាំ២០២០តទៅស្របតាមស្មារតីនៃអនុក្រឹត្យដែលខ្ញុំបានគូសបញ្ជាក់ខាងលើនេះ។

**ទីមួយៈ** <u>អំពីការរៀបចំផ្សព្វផ្សាយអនុក្រឹត្យ</u>

ជារួម អនុក្រឹត្យទាំងនេះបានកំណត់អំពីការកែសម្រួលក្នុងទ្រង់ទ្រាយដ៏ធំមួយនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈបច្ចុប្បន្នរបស់យើង ដែលតម្រូវឱ្យមានការផ្លាស់ប្តូរនូវនីតិវិធី និងរបៀបរបបបំពេញការងាររបស់មន្ត្រីសាធារណៈជាច្រើន និងតម្រូវឱ្យមានការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅអំពីបែបផែនថ្មីនៃការប្រាស្រ័យទាក់ទងរបស់ខ្លួនជាមួយនឹងប្រព័ន្ធគ្រប់គ្រងនៃស្ថាប័នសាធារណៈទាំងនេះពាក់ព័ន្ធទៅនឹងការផ្តល់សេវាសាធារណៈនានា។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវរៀបចំឱ្យមានការផ្សព្វផ្សាយជាបន្ទាន់នូវខ្លឹមសារនៃអនុក្រឹត្យដល់ថ្នាក់ដឹកនាំសំខាន់ៗនានារបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមបញ្ចូលទាំងអង្គការសង្គមស៊ីវិលនានាផងដែរ។ ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ត្រូវទទួលខុសត្រូវបន្តផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យទាំងនេះឱ្យបានទូលំទូលាយដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ។

**ទីពីរៈ** <u>អំពីការរៀបចំលិខិតបទដ្ឋាន និងឯកសារណែនាំបច្ចេកទេសនានា</u>

ដើម្បីធានាឱ្យរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចចាប់ផ្តើមអនុវត្តចាប់ពីដើមឆ្នាំ ២០២០តទៅ តម្រូវឱ្យមានការរៀបចំនូវលិខិតបទដ្ឋាន និងឯកសារណែនាំបច្ចេកទេសនានាដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារក្នុងវិស័យនីមួយៗដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

នៅមុនដំណាច់ឆ្នាំនេះ អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃត្រូវសហការជាមួយក្រសួងសុខាភិបាលក្នុងការរៀបចំនូវប្រកាសអន្តរក្រសួងមួយស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃមន្ទីរសុខាភិបាលរបស់រដ្ឋបាលរាជធានី ខេត្ត និងរៀបចំការណែនាំអំពីកម្មវិធី និងរបៀបរៀបចំការប្រកាសដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធនេះនៅតាមរាជធានី និងខេត្តនីមួយៗ។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាលក៏ត្រូវណែនាំឱ្យរដ្ឋបាលរាជធានី ខេត្តរៀបចំចាត់តាំងតំណាងថ្នាក់ដឹកនាំរបស់ខ្លួនចូលរួមជាអធិបតីក្នុងពិធីប្រកាសដាក់ឱ្យដំណើរការនូវរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗឱ្យបានមុនដំណាច់ឆ្នាំ២០១៩ នេះផងដែរ។

**ទីបី៖ <u>អំពីការផ្ទេរបុគ្គលិក</u>**

ផ្អែកតាមការសិក្សាលើទិន្នន័យ និងស្ថានភាពជាក់ស្តែងនៃបុគ្គលិករបស់ការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ យើងពិនិត្យឃើញមានបុគ្គលិកចំនួនប្រមាណ២០.០០០នាក់ របស់ក្រសួងស្ថាប័នដែលកំពុងបម្រើការងារនៅតាមការិយាល័យជំនាញនានាចំនួនជិត ២.០០០ ការិយាល័យ។ ចំនួននេះមិនទាន់គិតបញ្ចូលនូវមន្ត្រីអប់រំជាគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សាបឋមសិក្សា មតេយ្យសិក្សា និងគ្រឹះស្ថានអប់រំក្រៅប្រព័ន្ធនៅក្រុង ស្រុកទាំង១៤នៅខេត្តបាត់ដំបង និងមន្ត្រីសុខាភិបាលដែលកំពុងបំពេញការងារក្នុងរចនាសម្ព័ន្ធក្រសួងសុខាភិបាលនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេសដែលត្រូវផ្ទេរទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនោះឡើយ។

អាស្រ័យហេតុនេះ ក្នុងកិច្ចដំណើរការផ្ទេរក្របខ័ណ្ឌនៃការគ្រប់គ្រងមន្ត្រីក្នុងបរិមាណដ៏ច្រើន និងមានការពាក់ព័ន្ធទៅនឹងក្រសួង វិស័យជាច្រើនបែបនេះ តម្រូវឱ្យ គ.ជ.អ.ប រៀបចំបង្កើតនូវក្រុមការងារអន្តរក្រសួងមួយដែលរួមមានប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ជាសមាជិកក្រោមការដឹកនាំ និងសម្របសម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីជួយ គ.ជ.អ.ប ក្នុងការរៀបចំ និងដាក់ចេញនូវសេចក្តីសម្រេចស្តីពីការផ្ទេររួមគ្នានូវបុគ្គលិកពីក្រសួងវិស័យផ្សេងៗគ្នា ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឱ្យបានមុនឆ្នាំ២០២០។ សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារនឹងដាក់ចេញនៅចុងសប្តាហ៍នេះ ដូច្នេះខ្ញុំសង្ឃឹមថា ក្រុមការងារនឹងចាប់ផ្តើមការងាររបស់ខ្លួនជាបន្ទាន់ចាប់ពីសប្តាហ៍ក្រោយទៅ ដើម្បីធានាដល់ការរៀបចំផ្ទេរបុគ្គលិកទាំងនោះឱ្យបានទាន់ពេលវេលាកំណត់។ ទោះបីកិច្ចការនេះត្រូវរៀបចំចាត់ចែងដោយថ្នាក់ជាតិ ក្នុងន័យធានាដោះស្រាយបញ្ហានេះក្នុងដំណាក់កាលអន្តរកាលដ៏ចាំបាច់មួយ ប៉ុន្តែក្រុមការងារចាំបាច់ត្រូវធានាឱ្យមានការចូលរួមផ្តល់យោបល់ពីតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗផងដែរ។

**ទីបួន៖ <u>អំពីការផ្ទេរធនធានហិរញ្ញវត្ថុ</u>**

ការផ្ទេរមុខងារនានាចាំបាច់ត្រូវធានាឱ្យមានការផ្ទេរនូវធនធានហិរញ្ញវត្ថុភ្ជាប់ទៅជាមួយដើម្បីធានាដល់ប្រសិទ្ធិភាពនៃការអនុវត្តមុខងារទាំងនោះ។ ធនធានហិរញ្ញវត្ថុ គឺសំដៅទៅធនធានថវិកា និងទ្រព្យសម្បត្តិដែលត្រូវប្រើប្រាស់សម្រាប់ការបំពេញមុខងារទាំងនោះ។ ជារួម យោងតាមការសម្រប

សម្រួលរបស់លេខាធិការដ្ឋាន គ.ជ.អ.ប មកទល់បច្ចុប្បន្ននេះ រួមមានក្រសួងចំនួន៨ ដែលបានបញ្ជូននូវព័ត៌មានស្តីពីចំនួនធនធានហិរញ្ញវត្ថុ និងចំនួនបុគ្គលិកដែលក្រសួងគ្រោងផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំសូមស្នើឱ្យក្រសួង ស្ថាប័នដទៃទៀតយកចិត្តទុកដាក់បញ្ជូនព័ត៌មានទាំងនេះមក គ.ជ.អ.ប ឱ្យបានឆាប់រហ័សដើម្បីធ្វើជាមូលដ្ឋានក្នុងការបន្តពិនិត្យពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការរៀបចំកំណត់អំពីចំនួនថវិកាជាក់លាក់ និងសមស្រប ព្រមទាំងការរៀបចំលិខិតបទដ្ឋានបច្ចេកទេសនានាដើម្បីផ្ទេរធនធានទាំងនេះឱ្យបានទាន់ពេលវេលាទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌក្នុងការចាប់ផ្តើមបំពេញមុខងារនានាប្រកបដោយប្រសិទ្ធិភាព។

ក្នុងករណីដែលទ្រព្យសម្បត្តិជាអចលនទ្រព្យមួយចំនួនពុំអាចមានលទ្ធភាពរៀបចំផ្ទេរទាន់ពេលមុនដំណាច់ឆ្នាំនេះ ក្រសួង ស្ថាប័ននានាត្រូវអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រើប្រាស់នូវទ្រព្យសម្បត្តិទាំងនោះជាបណ្តោះអាសន្ន និងត្រូវបន្តរៀបចំផ្ទេរទ្រព្យសម្បត្តិឱ្យបានមុនដំណាច់ឆមាសទី១ ឆ្នាំ២០២០ខាងមុខនេះ។

**ទីប្រាំ៖ <u>អំពីការបណ្តុះបណ្តាល</u>**

ជារួម វគ្គបណ្តុះបណ្តាលមានលក្ខណៈចាំបាច់មួយចំនួនត្រូវរៀបចំសម្រាប់មន្ត្រីជំនាញមួយចំនួនរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅទូទាំងប្រទេសឱ្យបានមុនដំណាច់ឆ្នាំនេះ។ មុខជំនាញដែលត្រូវបំពាក់បំប៉នបន្ថែមជាបន្ទាន់ដល់មន្ត្រីជំនាញទាំងនោះ រួមមានដូចជា ជំនាញគ្រប់គ្រងការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គលិកជាដើម។ ក្រៅពីនេះ វគ្គបណ្តុះបណ្តាលស្តីពីភាពដឹកនាំក៏ត្រូវរៀបចំបន្តសម្រាប់ថ្នាក់ដឹកនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវសហការជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលទាំងនោះដោយផ្អែកលើគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិកដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្ស។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ខាងលើនេះគឺជាសកម្មភាពជាអទិភាពបំផុតដែលយើងបានពិភាក្សា និងឯកភាពគ្នាក្នុងកិច្ចប្រជុំលើទី១៧ របស់ គ.ជ.អ.ប នាខែកន្លងមកនេះ សម្រាប់ធានាដល់ការចាប់ផ្តើមអនុវត្តតាមស្មារតីនៃអនុក្រឹត្យស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ យ៉ាងណាមិញយើងនៅមានសេសសល់កិច្ចការជាច្រើនទៀតដែលត្រូវបន្តដោះស្រាយសម្រាប់ឆ្នាំ២០២០ខាងមុខនេះដែលជាឆ្នាំទីមួយនៃការចាប់ផ្តើមការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនាមជារដ្ឋបាលផ្តល់សេវាដោយផ្ទាល់លើវិស័យសាធារណៈសំខាន់ៗមួយចំនួនផង និងជាឆ្នាំចុងក្រោយនៃកម្មវិធីជាតិរយៈពេល ១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផងដែរ។

អាស្រ័យហេតុនេះ ឆ្នាំ២០២០ នឹងក្លាយទៅជាឆ្នាំដែលមានសារៈសំខាន់បំផុតសម្រាប់ការងារ

កំណែទម្រង់របស់យើង ដែលតម្រូវឱ្យយើងខិតខំប្រឹងប្រែងរួមគ្នាដើម្បីគាំទ្រ និងលើកកម្ពស់សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលទ្ធភាពពេញលេញក្នុងការផ្តល់សេវាសាធារណៈចាំបាច់នានាយ៉ាងល្អប្រសើរស្របតាមគោលដៅចុងក្រោយនៃកម្មវិធីជាតិ១០ឆ្នាំរបស់យើង។

ក្នុងន័យនេះ ខ្ញុំសូមផ្តល់នូវការណែនាំបន្ថែមអំពីកិច្ចការជាគន្លឹះមួយចំនួនដែលយើងត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការរៀបចំ និងអនុវត្តក្នុងផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២០របស់យើង ដែលរួមមានដោយខាងក្រោម៖

**ទីមួយ៖** <u>អំពីការលើកកម្ពស់តួនាទី សមត្ថភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការផ្តល់សេវាសាធារណៈចាំបាច់នានា</u>

ដូចខ្ញុំបានគូសបញ្ជាក់រួចហើយ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីជំរុញឱ្យរដ្ឋបាលថ្នាក់ទាំងនេះក្លាយជាតួអង្គក្នុងនាមជាអ្នកផ្តល់សេវាដោយផ្ទាល់ជូនប្រជាពលរដ្ឋ។ នេះគឺជាការផ្លាស់ប្តូរដ៏ធំធេងមួយនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតម្រូវឱ្យក្រសួងស្ថាប័នពាក់ព័ន្ធរៀបចំនូវសកម្មភាពជាក់លាក់ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ខ្លួនសម្រាប់ជួយគាំទ្រឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចបំពេញមុខងារក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋកាន់តែប្រសើរឡើង។

ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចាំបាច់ត្រូវសហការជាមួយក្រសួងស្ថាប័ននានាដើម្បីធានាដល់ការផ្ទេរធនធានហិរញ្ញវត្ថុឱ្យបានសមស្របផ្អែកលើមុខងារនីមួយៗដែលបានផ្ទេរ និងរៀបចំការណែនាំឱ្យបានច្បាស់លាស់អំពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រងប្រើប្រាស់ធនធានទាំងនោះ ក៏ដូចជាបែបបទនៃការរៀបចំនូវគម្រោងថវិកាចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់បណ្តាឆ្នាំជាបន្តបន្ទាប់ទៀត។ ដោយឡែក ក្រសួងមុខងារសាធារណៈត្រូវទទួលខុសត្រូវក្នុងការជួយគាំទ្រដល់រដ្ឋបាលទាំងនេះអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក។ ជាមួយគ្នាដែរ ក្រសួងស្ថាប័ននានាដែលបានផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលទាំងនេះ ក៏ចាំបាច់ត្រូវដាក់ចេញជាបន្ទាន់នូវសេចក្តីណែនាំបច្ចេកទេស និងការកំណត់អំពីនិយាម ឬស្តង់ដានៃការផ្តល់សេវាពាក់ព័ន្ធនឹងមុខងារទាំងនោះឱ្យបានច្បាស់លាស់។

លេខាធិការដ្ឋាន គ.ជ.អ.ប និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃត្រូវរៀបចំនូវគម្រោងសកម្មភាពជាក់លាក់មួយចំនួន ព្រមទាំងសហការគ្នាឱ្យបានជិតស្និតជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា និងសមាគមរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីតាមដានត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍ក្នុងករណីចាំបាច់ដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលនៅមានភាពទន់ខ្សោយ។

យ៉ាងណាមិញ កិច្ចការនេះនឹងក្លាយទៅជាការទទួលខុសត្រូវមុនគេរបស់ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក ខណ្ឌនីមួយៗ។ អាស្រ័យហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវខិតខំប្រឹងពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយគំនិតឆ្នៃប្រឌិត និងស្មារតីទទួលខុសត្រូវយ៉ាងខ្ពស់

បំផុត និងត្រូវវាយការណ៍ជាបន្ទាន់អំពីបញ្ហាប្រឈមនានាដែលធ្វើឱ្យរាំងស្ទះដល់ការបំពេញការងារស្របតាមស្មារតីនៃអនុក្រឹត្យទាំង៤នេះ។

**ទីពីរះ** <u>អំពីការធានាប្រសិទ្ធភាពនៃការវិនិយោគរបស់រដ្ឋសម្រាប់ការអភិវឌ្ឍ ឃុំ សង្កាត់</u>

យើងទាំងអស់គ្នាបានដឹងហើយថាចាប់ពីឆ្នាំ២០២០ តទៅ រាជរដ្ឋាភិបាលបានសម្រេចចិត្តផ្ដល់ធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលឃុំ សង្កាត់មានចំនួនទ្វេដងបើប្រៀបធៀបនឹងឆ្នាំ២០១៩។ ថវិកាដែលបានផ្ដល់បន្ថែមនេះមានគោលបំណងសំខាន់គឺ លើកកម្ពស់ការអភិវឌ្ឍឃុំ សង្កាត់ ទាំងឡាយ។ រដ្ឋបាលឃុំសង្កាត់ មានសិទ្ធិចាត់ចែងប្រើប្រាស់នូវធនធានទាំងនេះ ផ្អែកទៅលើតម្រូវការជាអទិភាពជាក់ស្ដែងរបស់មូលដ្ឋាននីមួយៗ ប៉ុន្តែការចាត់ចែងធនធានទាំងនេះត្រូវមានលក្ខណៈសមស្របតាមគោលការណ៍ និងនីតិវិធីនានាដែលបានកំណត់នៅក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់មូលនិធិឃុំ សង្កាត់។

នេះជាការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលដោយផ្អែកទៅលើការមើលឃើញអំពីប្រសិទ្ធភាពនៃការវិនិយោគទៅលើគម្រោងមូលនិធិឃុំ សង្កាត់នានា។ យើងទាំងអស់គ្នាជឿជាក់ថា ក្នុងរយៈពេលជាច្រើនកន្លងមកនេះ ក្រុមប្រឹក្សាឃុំ សង្កាត់កាន់តែមានសមត្ថភាព និងបទពិសោធន៍ក្នុងការចាត់ចែងប្រើប្រាស់នូវធនធានរបស់ខ្លួនសម្រាប់អនុវត្តគម្រោងអភិវឌ្ឍនានា ប៉ុន្តែរដ្ឋបាលទាំងនេះនៅត្រូវការការគាំទ្រជំនួយបច្ចេកទេស ក្នុងការរៀបចំសិក្សា និងអនុវត្តគម្រោងរបស់ខ្លួនពីថ្នាក់លើនៅឡើយ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ យន្តការផ្ដល់ជំនួយបច្ចេកទេសពីថ្នាក់រាជធានី ខេត្តដែលធ្លាប់ពឹងផ្អែកភាគច្រើនលើទីប្រឹក្សាដែលផ្ដល់ឱ្យដោយ គ.ជ.អ.ប កំពុងធ្លាក់ចុះគួរឱ្យព្រួយបារម្ភក្នុងពេលដែលពុំមានការបន្តគាំទ្រពីទីប្រឹក្សានានា ហើយជាមួយគ្នានេះក៏មានលេចចេញនូវបាតុភាពមិនប្រក្រតីមួយចំនួនបង្កឡើងដោយមន្ត្រីខិលខូចមួយចំនួនដែលបានឆ្លៀតប្រើអំណាចគាបសង្កត់យកនូវផលប្រយោជន៍មិនត្រឹមត្រូវពីការផ្ដល់ជំនួយបច្ចេកទេសនេះដែរ។

ពាក់ព័ន្ធបញ្ហានេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ រៀបចំតាមដានត្រួតពិនិត្យមើល និងពង្រឹងឡើងវិញនូវបែបផែននៃការគាំទ្រជំនួយបច្ចេកទេសដល់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដោយពិនិត្យមើលពីលទ្ធភាពរវាងរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬវិស័យឯកជនដែលអាចមានលទ្ធភាពផ្ដល់ការគាំទ្រជំនួយបច្ចេកទេសដល់ឃុំ សង្កាត់យ៉ាងមានប្រសិទ្ធិភាព។

**ទីបីះ** <u>អំពីការពង្រឹងសមត្ថភាពរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន</u>

ផ្អែកលើការកែសម្រួលជាថ្មីនូវរចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចាំបាច់ត្រូវមានការរៀបចំការបណ្តុះបណ្តាលដែលមានផែនការច្បាស់លាស់ចាប់ពីឆ្នាំខាងមុខនេះតទៅ ដើម្បីលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចរបស់មន្ត្រីគ្រប់កម្រិតនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យមន្ត្រីទាំងនោះបំពេញការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ មានសីលធម៌ល្អ និងការទទួលខុសត្រូវខ្ពស់ក្នុងការបម្រើប្រជាពលរដ្ឋ។

ក្នុងន័យនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានចាំបាច់ត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានារៀបចំនូវផែនការ និងកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលជាបន្តបន្ទាប់ទាំងសម្រាប់ថ្នាក់ដឹកនាំ និងមន្រ្តីបច្ចេកទេសរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដោយប្រើប្រាស់នូវទីតាំងបណ្តោះអាសន្ននានាទាំងនៅរាជធានី និងតាមខេត្តនានាទន្ទឹមគ្នានឹងការខិតខំសហការជាមួយធនាគារអភិវឌ្ឍអាស៊ីដើម្បីជំរុញល្បឿននៃការរៀបចំគម្រោងសាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋានឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

ខ្ញុំក៏សូមឆ្លៀតឱកាសនេះ អំពាវនាវឱ្យមានការចូលរួមគាំទ្រទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍនានានៅក្នុងសកម្មភាពបណ្តុះបណ្តាល និងការសិក្សាដកពិសោធន៍ទាំងឡាយណាដែលមានលទ្ធភាពជួយពង្រឹងសមត្ថភាពមន្រ្តីរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌផងដែរ។

**ទីបួន៖ <u>អំពីការលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយ សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា</u>**

ជាការពិតណាស់ សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងវិស័យឯកជន គឺសុទ្ធសឹងជាតួអង្គនៅក្នុងសង្គម ដែលអាចបង្កើតបានជាដៃគូដ៏សំខាន់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធានាដល់ការលើកកម្ពស់ប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពនៃការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនានាជូនប្រជាពលរដ្ឋ។

កន្លងមកនេះ យើងឃើញមាននូវគំរូនៃកិច្ចសហការដ៏ជិតស្និត និងប្រកបផ្លែផ្កាវាងតួអង្គទាំងនេះនៅក្នុងការអនុវត្តនូវគម្រោងនានាជាច្រើនដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងការពង្រឹងអភិបាលកិច្ចមូលដ្ឋាន។

អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តសហការជាមួយអ្នកពាក់ព័ន្ធនានាប្រមូលផ្តុំនូវមេរៀនបទពិសោធន៍ល្អៗទាំងនោះ និងសិក្សាបន្ថែមទៅលើក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនានាដើម្បីជួយគាំទ្រដល់ការកសាងនូវភាពជាដៃគូរវាងតួអង្គដ៏សំខាន់ទាំងនេះឱ្យមានលក្ខណៈច្បាស់លាស់ និងទូលំទូលាយថែមទៀត។

**ទីប្រាំ៖ <u>អំពីការរៀបចំតាក់តែងកម្មវិធីជាតិដំណាក់កាលបន្ទាប់</u>**

នៅសល់រយៈពេលមួយឆ្នាំទៀត យើងនឹងបញ្ចប់កម្មវិធីរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ជាការពិតណាស់ នៅក្នុងរយៈពេលជិត១០ឆ្នាំនៃការអនុវត្តកម្មវិធីជាតិនេះ បើទោះបីមានបញ្ហាប្រឈមនានាដែលធ្វើឱ្យមានការយឺតយ៉ាវ ឬមិនអាចសម្រេចបាននូវគោលដៅមួយចំនួនដែលយើងបានគ្រោង ប៉ុន្តែជារួមយើងបានសម្រេចនូវសមិទ្ធិផលជាច្រើនបង្កើតបានជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយក្នុងការបន្តជំរុញកិច្ចដំណើរការកំណែទម្រង់ឱ្យឈានឆ្ពោះទៅមុខថែមទៀត។

ទោះជាយ៉ាងនេះក្តី ផ្អែកលើបរិបទជាក់ស្តែងរបស់ប្រទេសយើង កំណែទម្រង់ដែលមានលក្ខណៈស្មុគស្មាញនេះនៅតែត្រូវការពេលវេលា និងការដាក់ចេញនូវផែនទីបង្ហាញផ្លូវរយៈពេលវែងយ៉ាងច្បាស់លាស់មួយដើម្បីធានាឱ្យយើងសម្រេចបាននូវគោលបំណងចុងក្រោយនៃកំណែទម្រង់នេះ។

អាស្រ័យហេតុនេះ កិច្ចការដ៏ចម្បងមួយទៀតសម្រាប់ឆ្នាំ២០២០ខាងមុខ គឺការរៀបចំតាក់តែងនូវកម្មវិធីជាតិរយៈពេលវែងថ្មីមួយទៀតដែលត្រូវចាប់ផ្តើមអនុវត្តពីឆ្នាំ២០២១តទៅ។ ពាក់ព័ន្ធនឹងកិច្ចការដ៏សំខាន់នេះ ខ្ញុំសង្ឃឹមថានឹងទទួលបាននូវការចូលរួមចំណែកគាំទ្រទាំងការផ្តល់មតិយោបល់ និងការផ្តល់នូវជំនួយបច្ចេកទេសដល់លេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានតួនាទីដឹកនាំសម្របសម្រួលដល់ការតាក់តែងសេចក្តីព្រាងកម្មវិធីជាតិនេះដើម្បីដាក់ឆ្លងសុំការពិនិត្យ និងឯកភាពរបស់ គ.ជ.អ.ប មុននឹងដាក់ជូនរាជរដ្ឋាភិបាលអនុម័ត។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

មុននឹងបញ្ចប់ការផ្តល់មតិយោបល់របស់ខ្ញុំក្នុងពិធីបិទសិក្ខាសាលានេះ ខ្ញុំសូមគូសបញ្ជាក់អះអាងជាថ្មីអំពីការតាំងចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងកំណែទម្រង់សំខាន់ៗដទៃទៀតដើម្បីរួមចំណែកជំរុញល្បឿននៃការអភិវឌ្ឍប្រទេសជាតិ និងការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានភាពចម្រើនរុងរឿង។ ខ្ញុំសូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលនានាដែលបានផ្តល់ការគាំទ្រដល់កំណែទម្រង់នេះ ហើយសង្ឃឹមថាដៃគូទាំងអស់នឹងបន្តគាំទ្រដល់កិច្ចការដ៏សំខាន់នេះតទៅមុខទៀត។

ខ្ញុំសូមជូនពរអង្គសិក្ខាសាលាទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំសូមប្រកាសបិទកម្មវិធីសិក្ខាសាលានេះ។

សូមអរគុណ!